# ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបតំណាងសម្ព័ន្ធក្រុមហ៊ុន Meinhardt Pte Ltd នៃប្រទេសសិង្ហបុរី



នៅរសៀលថ្ងៃទី០៨ ខែ ឧសភា ឆ្នាំ២០១៤ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបប្រតិភូតំណាងសម្ព័ន្ធក្រុមហ៊ុន **Meinhardt Pte Ltd** នៃប្រទេសសិង្ហបុរី ដឹកនាំដោយលោក **Fabian Ong** នាយកក្រុមហ៊ុន **Consultant Holding Co.Ltd** ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។

លោក **Fabian Ong** នាយកក្រុមហ៊ុន **Consultant Holding Co.Ltd** បានជម្រាបជូនពីគោលបំណងនៃជំនួបពិភាក្សាថាៈ ប្រតិភូក្រុមហ៊ុនរបស់លោក មកកម្ពុជាជាលើកទី១ ដើម្បីសិក្សាស្វែងយល់ពីឱកាសវិនិយោគនៅកម្ពុជា ។

ជាការឆ្លើយតប ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានលើកឡើងពីកត្តា ០៤យ៉ាង ដែលជាឱកាសដ៏ប្រសើរសម្រាប់ការវិនិយោគនៅកម្ពុជាគឺកត្តាសន្តិភាព - ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច - តម្លាភាពនិងក្របខ័ណ្ឌច្បាប់ដែលអាចប៉ាន់ប្រមាណបាន និងភាពអនុគ្រោះពាណិជ្ជកម្មរបស់កម្ពុជា ដែលទទួលបានពីប្រទេសអភិវឌ្ឍន៍ និងប្រទេសជាដៃគូ សម្រាប់ការនាំចេញទំនិញដោយរួចពន្ធ និងមិនជាប់កូតា។ ឯកឧត្តម បានលើកឡើងពីយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលយកអភិបាលកិច្ចល្អជាស្នូល ជាមួយនិងយន្តការដោះស្រាយ តាមរយៈក្រុមការងារទាំង៨ រវាងរដ្ឋាភិបាល និង វិស័យឯកជន។ ក្នុងនោះ រយៈពេល០៦ ខែម្តង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នឹងចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងវេទិការការរវាងរាជរដ្ឋាភិបាល និងវិស័យឯកជន ដើម្បីដោះស្រាយនូវកង្វល់នានារបស់វិស័យឯកជន ។ ទន្ទឹមគ្នានោះ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានលើកឡើងពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើឱ្យប្រសើរនូវបរិយាកាសវិនិយោគទាំងក្នុងស្រុក និងក្នុងតំបន់ ដូចជាៈការបង្កើតតំបន់សេដ្ឋកិច្ចពិសេស(SEZ)-តំបន់ពាណិជ្ជកម្មសេរី (FTA) ដោយរួមបញ្ចូលនូវយន្តការកែទំរង់ជាច្រើន ជាពិសេសទៅទៀតច្បាប់កម្ពុជា បានអនុញ្ញាតឱ្យក្រុមហ៊ុនបរទេសអាចដាក់ដើមទុនរបស់ខ្លួន ១០០% មានសិទ្ធិជួលអចលនទ្រព្យ និងគ្រប់គ្រង

លំនៅដ្ឋានចាប់ពីជាន់ទី១បាន។ ទាក់ទងនិងវិស័យឧស្សាហកម្ម ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានបញ្ជាក់ថាៈ ជាវិស័យកំពុងមានសក្តានុពលនៅកម្ពុជា ដែលបច្ចុប្បន្នវិស័យនេះ បានដើរតួរយ៉ាងសំខាន់ ក្នុងខឿនសេដ្ឋកិច្ចជាតិ និងជាប្រវត្តិសាស្រ្តផងដែរ ដែលនៅឆ្នាំ២០១៣ កន្លងទៅនេះ វិស័យឧស្សាហកម្មទទួលបានកំណើននៃផលទុនជាតិសរុប ចំនួនជាង ២៨% លើសវិស័យកសិកម្ម ដែលធ្លាប់ជាវិស័យឈានមុខ ។

ជាមួយនិងការលើកឡើងពី សក្តានុពល លក្ខណៈអំណោយផល និងកត្តាលើកទឹកចិត្តផ្នែកវិនិយោគ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានអំពាវនាវឱ្យអ្នកវិនិយោគនៃប្រទេសសិង្ហបុរី ពិនិត្យលទ្ធភាពវិនិយោគលើវិស័យជាអាទិភាពមួយចំនួន ដូចជាៈឧស្សាហកម្មកែច្នៃ-ឧស្សាហកម្មកាត់ដេរសំលៀកបំពាក់និងស្បែកជើង-សំណង់- ទេសចរណ៍ -អចលនទ្រព្យ-សេវាកម្មនិងផ្សារទំនើបជាដើម ។

